THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២

ជូនចំពោះ ក្រុមគ្រួសារទាំងអស់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

កាលពីម្សិលមិញ ក្រុមប្រឹក្សាសាលារបស់យើងបានអនុម័តថវិការបស់ក្រសួងអប់រំសម្រាប់ ឆ្នាំសិក្សា ២០២២-២០២៣ ជាថវិកាដែលមានកម្រិតខ្ពស់បំផុតក្នុងកាចំណាយទៅលើសាលា និងសិស្សរបស់យើង តាំងពីថវិកា ឆ្នាំ ២០១១ មក។

កាលពីឆ្នាំមុន ក្រសួងអប់រំបានចំណាយរាប់រយលានដុល្លារបន្ថែមទៀតដើម្បី៖ បន្ថែមមុខតំណែងដែលមានការហ្វឹកហ្វឺនដែលតម្រូវតាមសេចក្តីត្រូវការរបស់សាលា។ ផ្តល់ប្រាក់រង្វាន់ដល់ការជ្រើសរើសអ្នកធ្វើការ និងរក្សាទុកបុគ្គលិកនៅតាមសាលា ដើម្បីបន្តការគាំទ្រដល់សិស្សរបស់យើង។ បង្កើន កម្មវិធី មុន និង ក្រោយ ម៉ោងរៀន នៅសាលា។ បង្កើនចំនួនអ្នកចិត្តសាស្ត្រ អ្នកឯកទេសផ្នែកបង្ហាត់កិច្ចការប្រចាំថ្ងៃ អ្នកឯកទេសផ្នែកបង្រៀនសិស្សឱ្យនិយាយ អ្នកប្រឹក្សាផ្នែកអាកប្បកិរិយា និងអ្នកឯកទេសផ្នែកឆ្លើយតបនឹងសន្តិសុខ និងការប៉ះទង្គិចធ្ងន់ធ្ងរនៅសាលា។ ពង្រីកកម្មវិធីសិក្សាក្នុងរដូវក្តៅ និងអ្វីៗជាច្រើនទៀត។ ឥឡូវនេះ យើងមានគ្រូបង្រៀនម្នាក់សម្រាប់សិស្ស ១២,៣ នាក់ និងបុគ្គលិកនៅសាលាម្នាក់សម្រាប់សិស្ស ៦,៥ នាក់។ ហើយយើងនៅមិនទាន់រួចរាល់នៅឡើយទេ។

សម្រាប់ ឆ្នាំសិក្សា ២០២២-២០២៣ ទោះជាមានការព្យាករណ៍ថា មានសិស្សតិចជាងពេលមុនៗនៅក្នុងក្រសួងអប់រំរបស់យើងក៏ដោយ យើងមានការបង្កើនថវិការបស់យើងបន្ថែមទៀតជាង ១៧៥ លានដុល្លារ។ ផ្អែកលើការស្ទង់មតិកែលម្អរបស់លោកអ្នក យើងចំណាយបន្ថែមទៀតទៅលើសាលា និងសិស្សរបស់យើង ដោយ៖

- បង្កើនម៉ោងទ្វេដងជាអចិន្ត្រៃយ៍ និងផ្តល់អត្ថប្រយោជន៍ពេញម៉ោងសម្រាប់ បុគ្គលិកផ្នែកសន្តិសុខ និងសកម្មភាពរបស់សិស្ស (Student Climate Staff)។
- បង្កើនចំនួនអ្នកផ្តល់ឱវាទ ទៅលើចំនួនសិស្ស
- បន្ថែមគ្រូបង្រៀនផ្នែកអប់រំពិសេស គ្រូបង្រៀនសិស្សដែលត្រូវការរៀនភាសាអង់គ្លេស និងអ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា

- ពង្រីកការកែលម្អបរិស្ថានដែលជំរុញយើងឱ្យខិតទៅជិតគោលដៅនៃការបញ្ជាក់ថាសាលាទាំងអស់ផុតពីគ្រោះថ្នាក់នៃសំណពុល នៅឆ្នាំ ២០២៤ និង
- គាំទ្រដល់ការដំឡើង ឧបករណ៍បង្ហូរទឹកផឹកដោយស្វ័យប្រវត្ត (hydration stations) ចំនួន ៨០០ ថែមទៀត នៅក្នុងសាលា ឱ្យហើយក្នុងឆ្នាំ ២០២៥ ឬមុននេះ។

យើងមានអំណរគុណចំពោះការបញ្ចូលថវិការបស់សហព័ន្ធតែម្តង ពី ច្បាប់សម្រាប់ផែនការស្តារអាមេរិកឡើងវិញ (American Recovery Plan Act) ដែលអាចធ្វើឱ្យមានការចំណាយយ៉ាងច្រើនទៅលើសាលា និងសិស្សរបស់យើងទៅបាន។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការងារដ៏អស្ចារ្យរបស់បុគ្គលិកគ្រប់រូបនៅក្រសួងអប់រំ នៅពេលដែលយើងប្រើប្រាក់ទាំងនេះដើម្បីគាំទ្រដល់តម្រូវការសង្គមអារម្មណ៍ និងការសិក្សារបស់សិស្សទាំងអស់របស់យើង។ ទីក្រុង និង រដ្ឋ នឹងអនុម័តថវិកានៅខែមិថុនានេះ ដែលនឹងមានឥទ្ធិពលដល់ថវិការបស់យើងផងដែរ។ រហូតដល់ពេលនោះ លោកអ្នកអាចស្វែងយល់បន្ថែមអំពីថវិការបស់ក្រសួងអប់រំនៅ ត្រង់នេះ។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite Jr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា